ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
Minsitry of Labour and Vocational Training

# ប.ស.ស. ហានិភ័យការងារ សម្រាប់បុគ្គលវិស័យសាធារណៈ



## មាន ប.ស.ស. មានការគាំពារពេលគ្រោះថ្នាក់ការងារ

## តើអ្វីទៅជាការធានារ៉ាប់រងផ្នែកហានិភ័យការងារ (គ្រោះថ្នាក់ការងារ ឬជំងឺវិជ្ជាជីវៈ)?

ការធានារ៉ាប់រងផ្នែកហានិភ័យការងារ (គ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ) គឺជាការធានាទៅលើគ្រោះថ្នាក់ទាំងឡាយណាដែលកើតឡើងចំពោះរូបកាយមន្ត្រីសាធារណៈក្នុងពេលបំពេញការងារទាំងនៅកន្លែងការងារឬក្នុងពេលធ្វើការជូនក្រសួង ស្ថាប័ន អង្គភាពរបស់ខ្លួន និងទាំងពេលធ្វើដំណើរទាំងទៅទាំងមកពីផ្ទះទៅកន្លែងធ្វើការ ដោយមិនវាងទៅកន្លែងណាផ្សេងសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន។



គ្រោះថ្នាក់ការងារ

ការធានារ៉ាប់រងនេះក៏ធានាផងដែរ ប្រសិនបើមន្ត្រីសាធារណៈទទួលរងនូវជំងឺវិជ្ជាជីវៈ ទោះជំងឺនោះកើតឡើងក្នុងកំលុងពេលបំពេញការងារឬក្នុងពេលណាមួយក្រោយបំពេញការងារក៏ដោយ ឱ្យតែជាជំងឺដែលបង្កឡើងដោយសារតែការបំពេញការងារ។

**ចំណាំ៖** ចំពោះគ្រោះថ្នាក់ដែលបង្កឡើងដោយចេតនាផ្ទាល់ខ្លួន មិនទទួលបានតាវកាលិកផ្នែកហានិភ័យការងារនោះទេ។

បន្ទាប់ពីរងគ្រោះថ្នាក់ការងារ អត្ថប្រយោជន៍ដែលគាត់នឹងទទួលបានរួមមាន៖

### ១ ផ្តល់ការព្យាបាល និងថែទាំវេជ្ជសាស្ត្រ

ការព្យាបាល និងថែទាំវេជ្ជសាស្ត្រត្រូវធ្វើឡើងនៅក្នុងមន្ទីរពេទ្យដៃគូរបស់ ប.ស.ស.។ ជនរងគ្រោះអាចទៅព្យាបាលនៅមន្ទីរពេទ្យដែលមិនមែនជាដៃគូរបស់ ប.ស.ស. បានតែក្នុងករណីសង្គ្រោះបន្ទាន់តែប៉ុណ្ណោះ។



ករណីគ្រោះថ្នាក់ដែលកើតឡើងនៅកន្លែងធ្វើការ ឬគ្រោះថ្នាក់ពេលធ្វើដំណើរ ជនរងគ្រោះត្រូវបញ្ជូនទៅសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យដែលនៅជិតបំផុត។ បន្ទាប់មកត្រូវបញ្ជូនជនរងគ្រោះទៅកាន់មន្ទីរពេទ្យដៃគូរបស់ ប.ស.ស.។

ប.ស.ស. ចេញការចំណាយសង្គ្រោះបន្ទាន់ទៅតាមតម្លៃនៃមន្ទីរពេទ្យដែលបានចុះកិច្ចព្រមព្រៀង។



### ២ ការផ្តល់ប្រាក់បំណាច់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន

ក្នុងរយៈនៃការសម្រាកព្យាបាលមុខរបួស ឬជំងឺដែលបណ្តាលមកពីហានិភ័យការងារនៅតាមមូលដ្ឋានសុខាភិបាល និងរយៈពេលសម្រាកក្រោយការចេញពីមូលដ្ឋានសុខាភិបាល តាមវេជ្ជបញ្ជាដែលចេញដោយគ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យទទួលស្គាល់ដោយ ប.ស.ស. ប្រាក់បៀវត្សរបស់សាមីជនរងគ្រោះត្រូវបានរក្សាទុកដដែល។



## ៣ ការផ្តល់វិភាជន៍ និងធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍



មន្ត្រីសាធារណៈ បាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី ២០% ឡើងទៅ ប.ស.ស. នឹងផ្តល់ជាប្រាក់ឧបត្ថម្ភ (ប្រាក់ធនលាភជូនរៀងរាល់មួយ(១)ខែម្តង ហើយបើតម្រូវឲ្យមានអ្នកថែទាំ នោះអ្នកថែទាំនឹងទទួលបានប្រាក់ ៥០% នៃប្រាក់ឧបត្ថម្ភដែលជនរងគ្រោះនោះត្រូវទទួលបាន។

ប.ស.ស. នឹងផ្តល់ប្រាក់វិភាជន៍តែម្តងគត់(បើកផ្តាច់)ជូនមន្ត្រីសាធារណៈពិការក្រោម ២០%។

**ចំណាំ៖** ប្រាក់ឧបត្ថម្ភដែល ប.ស.ស. ផ្តល់ជូនត្រូវចាត់ទុកជាបណ្តោះអាសន្នជានិច្ច និងត្រូវពិនិត្យឡើងវិញជារៀងរាល់ឆ្នាំតាមការកំណត់របស់ ប.ស.ស.។

## ៤ សេវាស្តារនីតិសម្បទា



បន្ទាប់ពីទទួលបានសេវាព្យាបាល និងថែទាំសុខភាពដែលទទួលរងដោយហានិភ័យការងារ បណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ជនរងគ្រោះមានសិទ្ធិទទួលបានសេវាវេជ្ជសាស្ត្រ សេវាបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ និងសេវាសង្គមដូចខាងក្រោម៖



▶▶ **សេវាវេជ្ជសាស្ត្រ៖** សំដៅដល់ការផ្តល់ការជួសជុល ឬការផ្តល់ជាថ្មីអវៈយវៈសិប្បនិម្មិតរណប ឬឧបករណ៍ជំនួយការហ្វឹកហាត់កាយសម្បទាឡើងវិញ ការព្យាបាលដោយចលនា និងសេវាវេជ្ជសាស្ត្រដទៃទៀត។

▶▶ **ការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ៖** សំដៅដល់ការតម្រង់ទិសវិជ្ជាជីវៈ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីមានឱកាសទទួលបានការងារជាថ្មី ឬប្រកបមុខរបរផ្ទាល់ខ្លួន។ ប.ស.ស. អាចជួយសម្របសម្រួលរកការងារឱ្យធ្វើស្របតាមលក្ខណៈសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារតួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែង។

▶▶ **សេវាសង្គម៖** ទទួលបាននូវការប្រឹក្សា ការតម្រង់ទិស ការអប់រំចិត្តសាស្ត្រ ក្នុងគោលបំណងឲ្យសម្របខ្លួនទៅនឹងតម្រូវការគ្រួសារ សហគមន៍ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ។

## ៥ អ្នកទទួលរងហានិភ័យការងាររហូតដល់ស្លាប់

ប្រសិនបើមន្ត្រីសាធារណៈមានគ្រោះថ្នាក់ការងាររហូតដល់បាត់បង់ជីវិតក្នុងអំឡុងពេលបម្រើការងារនោះ ប.ស.ស.៖

▶▶ ចេញថ្លៃដឹកសពទៅដល់ផ្ទះ (ពីកន្លែងទទួលមរណភាព ទៅដល់លំនៅឋានរបស់សព)ផ្អែកតាមតម្លៃរបស់មន្ទីរពេទ្យដៃគូ ប.ស.ស.។




▶▶ ផ្តល់ប្រាក់វិភាជន៍ចំនួន ១០លានរៀល សម្រាប់ការចាត់ចែងធ្វើបុណ្យសពតាមបែបសាសនា។





រីឯសមាជិកគ្រួសារ(ជាសិទ្ធិវន្ត)ដែលនៅក្នុងបន្ទុករបស់ជនរងគ្រោះវិញ ប្រាក់ឧបត្ថម្ភអាចនឹងត្រូវផ្តល់ជូនទៅតាមករណីដូចខាងក្រោម៖

▶▶ ករណីជនរងគ្រោះនៅលីវ ផ្តល់ប្រាក់ឧបត្ថម្ភជូនឪពុកម្តាយ ឬចាស់ជរានៅក្នុងបន្ទុករបស់ជនរងគ្រោះ ដែលមានអាយុចាប់ពី៦០ឆ្នាំឡើងទៅ ឬមានជំងឺប្រចាំកាយ និងមិនប្រកបមុខរបរដែលមានចំណូល ឬប្រាក់សោធននិវត្តន៍ ឬសោធនជរាភាព។







▶▶ ករណីរៀបការមិនមានសំបុត្រអាពាហ៍ពិពាហ៍មិនផ្តល់ប្រាក់ឧបត្ថម្ភជូនប្តី ឬប្រពន្ធនោះទេ។

▶▶ ករណីរៀបការមានសំបុត្រអាពាហ៍ពិពាហ៍(អេតាស៊ីវិល) ប.ស.ស. ផ្តល់ប្រាក់ឧបត្ថម្ភជូនប្តី ឬប្រពន្ធមួយជីវិត ប្រសិនជាមិនមានចំណងអាពាហ៍ពិពាហ៍ជាថ្មី កូនក្នុងបន្ទុកឧបត្ថម្ភដល់អាយុមិនលើសពី ២១ឆ្នាំ។ កូនពិការ ឬមានជំងឺរ៉ាំរ៉ៃ ហើយមិនអាចប្រកបការងារ ឬមុខរបរដែលមានប្រាក់ចំណូលត្រូវផ្តល់ធនលាភឧត្តរជីវី(ប្រាក់ឧបត្ថម្ភ)អស់មួយជីវិត។



**លក្ខខណ្ឌ៖** គ្រប់ករណីទាំងអស់ អ្នកទទួលប្រាក់ឧបត្ថម្ភត្រូវមានឯកសារបញ្ជាក់ពីទំនាក់ទំនងរវាងពួកគាត់ និងជនរងគ្រោះដែលស្លាប់នោះ។ ឯកសារបញ្ជាក់រួមមានសៀវភៅគ្រួសារ សៀវភៅស្នាក់នៅ សំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងសេចក្តីចម្លងសំបុត្រកំណើតកូន។

**👉 មន្ត្រីសាធារណៈនៅពេលរងគ្រោះថ្នាក់ការងារ លោកអ្នកត្រូវជូនដំណឹងដូចខាងក្រោម៖**

- ត្រូវជូនដំណឹងទៅក្រសួង-ស្ថាប័នសាមី ឬជូនដំណឹងមក ប.ស.ស. តាមលេខទូរស័ព្ទបន្ទាន់ **១២៨៦ ឬ ១២៩៧** (មិនគិតថ្លៃ សេវាការហៅចូលគ្រប់ប្រព័ន្ធ) ក្នុងរយៈពេល **៤៨ម៉ោង** បន្ទាប់ពីគ្រោះថ្នាក់។

**👉 ក្រសួង-ស្ថាប័នសាមី ឬអ្នកតំណាងបន្ទាប់ពីទទួលបានព័ត៌មានករណីមន្ត្រីសាធារណៈទទួលរងហានិភ័យការងារ**

- ជូនដំណឹងបន្ទាន់មក ប.ស.ស. តាមរយៈលេខ **១២៨៦ ឬ ១២៩៧** ដើម្បីជួយសម្របសម្រួលជនរងគ្រោះទៅមន្ទីរពេទ្យ។
- ផ្ញើរបាយការណ៍មក ប.ស.ស. តាមរយៈអ៊ីមែល៖ **benefit@nssf.gov.kh** ឬតាមរយៈទីស្នាក់ការ ប.ស.ស. ដែលនៅជិតបំផុត។
- ត្រូវបញ្ជូនរបាយការណ៍ហានិភ័យការងារ និងឯកសារពាក់ព័ន្ធមក ប.ស.ស. ក្នុងរយៈពេលយ៉ាងយូរ **៤៨ម៉ោង ឬ ១២៩៧** នៃថ្ងៃធ្វើការ បន្ទាប់ពីមន្ត្រីសាធារណៈទទួលរងហានិភ័យការងារ។